# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៧៥ រប-៩៧

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>សូមជម្រាបមក</u>**

**លោក ប្រធានតុលាការកំពូល**
**លោក អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល**
**លោក ប្រធានសាលាឧទ្ធរណ៍ស្តីទី**
**លោក អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**
**លោក អគ្គព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង**

<u>សូមជ្រាប</u>

**<u>កម្មវត្ថុ:</u>** ការឆ្លើយតបនិងសារព័ត៌មាន ដែលចុះផ្សាយអត្ថបទពាក់ពន្ធ័និងការងាររបស់តុលាការ ។

ខ្ញុំសូមជម្រាបអស់លោកជ្រាបថា សព្វថ្ងៃនេះមតិសាធារណៈ ជាពិសេសសារព័ត៌មានមិនពេញចិត្តនិងការងាររបស់តុលាការអយ្យការទេ ហើយសរសេរទិទៀនជាញឹកញយ ។

យើងត្រូវទទួលស្គាល់ថាការមិនពេញចិត្តបណ្តាលមកពីការមិនយល់របស់គេចំពោះហេតុផល ដែលនាំឱ្យតុលាការសម្រេចយ៉ាងនេះឬយ៉ាងនោះ ជាពិសេសភាគច្រើនគេរៀបរាប់តាមការរាយការណ៍ របស់តែភាគីម្ខាងពោលគឺប្រាស់ចាកការពិតក្នុងសំណុំរឿង ហើយរហូតដល់មានការបង្ខូចកិត្តិយសតុលាការទៀតផង ។

ដើម្បីបំភ្លឺមតិសាធារណៈ ការពារកិត្តិយសរបស់អស់លោកនិងកិត្តិនាមរបស់តុលាការអយ្យការ ខ្ញុំសូមអស់លោកសរសេរទៅពន្យល់គេវិញ នៅពេលដែលមានអត្ថបទប៉ះពាល់ដល់អស់លោក ឬដល់តុលាការសុំឱ្យគេចុះផ្សាយអំពីការពិតតាមសេចក្តីបំភ្លឺរបស់យើង ដោយប្រើពាក្យសម្តីអព្យាក្រិត្យកុំឱ្យមានរឿងជាមួយអ្នកសារព័ត៌មានឱ្យសោះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**